# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
***Nation - Religion - King***

ក្រសួងពាណិជ្ជកម្ម
*Ministry of Commerce*
លេខ ១៣៧ ព.ណ ចបព.ប្រក

ភ្នំពេញ, ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៧

# ប្រកាស
## ស្តីពី
## ការដាក់ពាក្យសម្គាល់ទ្រង់ទ្រាយក្រុមហ៊ុន

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ១៩១ ពណ ចបព ប្រក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម

## សម្រេច

**ប្រការ១~.**

កំណត់ឲ្យដាក់ពាក្យសម្គាល់ទ្រង់ទ្រាយក្រុមហ៊ុននៅខាងចុង ឬ ខាងក្រោមនាមករណ៍របស់ក្រុមហ៊ុន ដោយប្រើពាក្យពេញ ឬ ជាអក្សរកាត់បាន។



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ(៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat* *Phone/Facsimile: (855)-23 866 469*

**ប្រការ២~.**

នាមករណ៍របស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់ពាក្យសម្គាល់ទ្រង់ទ្រាយ ដោយពាក្យពេញថា "ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត" ឬ អក្សរកាត់ថា "ឯ.ក" នៅខាងចុង ឬខាងក្រោមនាមករណ៍របស់ក្រុមហ៊ុន។

**ប្រការ៣~.**

នាមករណ៍របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់ពាក្យសម្គាល់ទ្រង់ទ្រាយ ដោយពាក្យពេញថា "ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត" ឬអក្សរកាត់ថា "ម.ក" នៅខាងចុង ឬខាងក្រោម នាមករណ៍របស់ក្រុមហ៊ុន។

**ប្រការ៤~.**

នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវដាក់ពាក្យសម្គាល់ទ្រង់ទ្រាយដោយពាក្យពេញថា "ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ" ឬ អក្សរកាត់ថា "ស.ទ" នៅខាងចុង ឬខាងក្រោម នាមករណ៍របស់ក្រុមហ៊ុន។

**ប្រការ៥~.**

នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវដាក់ពាក្យសម្គាល់ទ្រង់ទ្រាយដោយពាក្យពេញថា "ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត" ឬ អក្សរកាត់ថា "ស.ក" នៅខាងចុង ឬខាងក្រោម នាមករណ៍របស់ក្រុមហ៊ុន។

**ប្រការ៦~.**

ខ្លឹមសារនៃប្រកាសទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៧~.**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ប្រធានអង្គភាពនានាចំណុះក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចម្លងជូន:**

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ទីស្តីការគណៈរដ្ឋមន្ត្រី
ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រចាំការ **គាត ឈន់**
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
អាជ្ញាធរសវនកម្មជាតិ
ក្រសួងស្ថាប័នពាក់ព័ន្ធ
អង្គភាពប្រឆាំងអំពើពុករលួយ
អគ្គនាយកដ្ឋានកាំកុងត្រូល
អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
អគ្គនាយកដ្ឋានពន្ធដារ
គ្រប់រដ្ឋបាលរាជធានី ខេត្ត
គ្រប់មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត
សភាពាណិជ្ជកម្មកម្ពុជា
សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
សហព័ន្ធស្រូវអង្ករកម្ពុជា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ក្រសួងពាណិជ្ជកម្ម

ស៊ុន ចាន់ថុល